01325370

E389/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / 09 / 2016
ម៉ោង (Time/Heure): 15:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម យ៉ា សុខន ជ. ប្រធាន
ចៅក្រម **Jean-Marc LAVERGNE**
ចៅក្រម យូរ ឧត្តរា
ចៅក្រម **Claudia FENZ**
ចៅក្រម ធូ មណី

កាលបរិច្ឆេទ: ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៦
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើកទីប្រាំ ស្តីពីសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ និង ដីកាបង្គាប់ឲ្យធ្វើតេស្តទៅលើបញ្ហាស្មារតីប្រចាំត្រីមាស

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GIRAUD

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

## ១. ប្រវត្តិនីតិវិធី

១. អនុលោមតាមវិធាន ៣២ នៃវិធានផ្ទៃក្នុង តាមគំនិតផ្តួចផ្តើមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង បានចាត់តាំងអ្នកជំនាញពីររូបគឺ វេជ្ជបណ្ឌិត CHAN Kin Ming និង វេជ្ជបណ្ឌិត ហួត លីនណា ("អ្នកជំនាញ") ដើម្បីពិនិត្យវាយតម្លៃជនជាប់ចោទ និង ធ្វើរបាយការណ៍ស្តីពីសម្បទារបស់គាត់ ក្នុងការចូលរួមសវនាការ[1]។ បន្ទាប់ពីបានពិនិត្យវាយតម្លៃជនជាប់ចោទទៅតាមសេចក្តីបង្គាប់ របស់អង្គជំនុំជម្រះរួចហើយ អ្នកជំនាញបានដាក់របាយការណ៍របស់ខ្លួននៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦[2]។ នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានសាកសួរភាគី នានាថាតើភាគីចង់សួរដេញដោលអ្នកជំនាញទៅលើរបាយការណ៍ និង មតិយោបល់របស់ពួកគេ នៅក្នុងសវនាការថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦ ដែរ ឬយ៉ាងណា[3]។ នៅថ្ងៃទី ២៧ និង ២៨ ខែ កក្កដា ឆ្នាំ ២០១៦ ភាគីនានា បានឆ្លើយតបតាមរយៈអ៊ីម៉ែលថា ភាគី មិនមានសំណួរសួរដេញ ដោលអ្នកជំនាញនោះឡើយ។ ហេតុដូច្នេះ សវនាការស្តីពីសម្បទារបស់ជនជាប់ចោទក្នុងការចូល រួមសវនាការពុំមានឡើយ។

២. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចចំនួនបួនលើកដោយឡែកពីគ្នាថា នួន ជា មានសម្បទា គ្រប់គ្រាន់ក្នុងការចូលរួមសវនាការ[4]។ សម្រាប់គោលបំណងនៃសេចក្តីសម្រេចនេះ អង្គជំនុំជម្រះ

---

[1] ដីកាចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ("ដីកា") ឯកសារ E389 ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៦។

[2] របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ៖ នួន ជា ("របាយការណ៍ស្តីពី នួន ជា") ឯកសារ E389/3 ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦។ របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ៖ ខៀវ សំផន ឯកសារ E389/4 ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦។ របាយ-ការណ៍ទាំងពីរបានដាក់ជូនជាឯកសារសម្ងាត់បំផុត ដោយសារតែវាជាបញ្ហាឯកជនរបស់បុគ្គល។

[3] អ៊ីម៉ែលពីអង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនភាគីចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦។

[4] សេចក្តីសម្រេចលើកទីបួនទៅលើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E329/7 ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ("សេចក្តីសម្រេចលើកទីបួនទៅលើសម្បទា")។ សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E301/11 ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤។ សេចក្តីសម្រេចលើកទីពីរលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E256/5 ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣។ សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និង លើសំណើរបស់ក្រុមមេធាវីការពារក្តី សុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ឯកសារ E115/3 ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១។

បានបង្គាប់ឱ្យអ្នកជំនាញរាយការណ៍ពីព័ត៌មានដែលអាចជួយឱ្យអង្គជំនុំជម្រះសម្រេចអំពីសម្បទារបស់ជនជាប់ចោទ អនុលោមទៅតាមលក្ខណៈវិនិច្ឆ័យដែលមានរៀបរាប់ទៅក្នុងសាលដីកាលើបណ្តឹងសាទុក្ខក្នុង *រឿងក្តី Strugar*[5]។

## ២. ការពិនិត្យវាយតម្លៃរបស់អ្នកជំនាញ

៣. អ្នកជំនាញបានពិនិត្យវាយតម្លៃលើ នួន ជា នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៦ និង បានពិនិត្យទៅលើរបាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍របស់គ្រូពេទ្យប្រចាំការនៅមន្ទីរឃុំឃាំង អ.វ.ត.ក និង មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅទីក្រុងភ្នំពេញ[6]។ នៅក្នុងរបាយការណ៍ស្តីពី នួន ជា អ្នកជំនាញបញ្ជាក់ថា នួន ជា ធ្លាប់មានជំងឺរ៉ាំរ៉ៃជាច្រើន ប៉ុន្តែសម្ពាធឈាម សំឡេងបេះដូង សភាពស្បែកស្លាំង ការដកដង្ហើម ចលនាសាច់ដុំ និង ការស្តាប់ឮរបស់គាត់ មានសភាពធម្មតាទាំងអស់[7]។

៤. នួន ជា បានត្អូញត្អែរពីការឈឺចង្កេះចាប់តាំងពីឆ្នាំ ២០០៧ មកម្ល៉េះ[8]។ អ្នកជំនាញរាយការណ៍ថា វេជ្ជបណ្ឌិតដែលព្យាបាលគាត់នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានកត់សម្គាល់ថា អាការៈឈឺចង្កេះរបស់គាត់នៅដដែលមិនប្រែប្រួលឡើយ ដោយអាការៈនេះធូរស្បើយវិញនៅពេលគាត់នៅស្ងៀម ហើយគាត់អាចក្រោកអង្គុយបានរយៈពេលខ្លី[9]។ វេជ្ជបណ្ឌិតដែលព្យាបាលគាត់បានបន្ថែមថា ទោះបីជាការធ្វើចលនារបស់គាត់យឺតជាងមុនក៏ដោយ ក៏គាត់នៅតែអាចដើរដោយខ្លួនឯងបានដោយប្រើដែកច្រត់ និង មានអ្នកជួយទប់គាត់តិចៗ[10]។ អ្នកជំនាញយល់ថា ការឈឺខ្នងរបស់គាត់ គឺ

---

[5] ដីកាចាត់តាំងអ្នកជំនាញ កថាខណ្ឌ ៦ ដែលដកស្រង់ចេញពីរឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Strugar* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY សំណុំរឿងលេខ IT-01-42-A សាលដីកា ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨ ("រឿងក្តី *Strugar*") កថាខណ្ឌ ៥៥។

[6] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៣, ៥, ៧។

[7] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៦, ១២។

[8] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៦។ សូមមើល សេចក្តីសម្រេចលើកទីបួនទៅលើសម្បទា កថាខណ្ឌ ៥។

[9] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ កថាខណ្ឌ ៧។

[10] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៧។

ពាក់ព័ន្ធនឹងវ័យចាស់ជរា និង របួសចាស់របស់គាត់ ប៉ុន្តែអ្នកជំនាញក៏បញ្ជាក់ដែរថា បញ្ហានេះមិនគួរប៉ះពាល់ដល់លទ្ធភាពរបស់គាត់ក្នុងការចូលរួមសវនាការឡើយ[11]។

៥. នួន ជា ក៏បានត្អូញត្អែរផងដែរពីអាការៈវិលមុខកាលពីមុន ដោយអាការៈនេះកើតឡើងម្តងម្កាលនៅពេលគាត់កម្រើកខ្លួន[12]។ អ្នកជំនាញយល់ថា អាការៈវិលមុខរបស់ នួន ជា គឺបណ្តាលមកពីការចុះខ្សោយសរសៃប្រសាទនៅត្រចៀកដោយសារភាពចាស់ជរា ប៉ុន្តែ អ្នកជំនាញបានបញ្ជាក់ថា បញ្ហានេះមិនគួរប៉ះពាល់ដល់លទ្ធភាពរបស់គាត់ក្នុងការចូលរួមសវនាការឡើយ[13]។ អ្នកជំនាញសន្និដ្ឋានថា នួន ជា មានសុខភាពល្អ បើគិតពីអាយុ និង ស្ថានភាពសុខភាពរុំារ៉ៃរបស់គាត់[14]។

៦. នៅក្នុងកិច្ចសម្ភាសរបស់គាត់ជាមួយអ្នកអ្នកជំនាញ នួន ជា អាចក្រោកអង្គុយបានរហូតដល់ទៅ ៦០ នាទី ដោយមិនបាច់មានអ្វីទប់ និង អង្គុយបានស្រួលនៅពេលផ្អែកទៅក្រោយ[15]។ នួន ជា អាចនិយាយឮៗ និង ច្បាស់ៗ និង ចាំបានថា គាត់ធ្លាប់បានជួបជាមួយអ្នកជំនាញកាលពីមុន ទោះបីជាគាត់មិនចាំឈ្មោះរបស់ពួកគាត់ក៏ដោយ[16]។ នួន ជា បានប្រាប់អ្នកជំនាញថា គាត់ជឿថា ភ្នែករបស់គាត់មិនមើលឃើញច្បាស់ទេ តែគាត់ស្តាប់ព័ត៌មានតាមវិទ្យុ និង អាចមើលគំនូសភូគោល និង ផែនទីពិភពលោក ដោយអាចរកឃើញប្រទេសនានាដែលបានលើកឡើងនៅក្នុងការផ្សាយព័ត៌មាននោះបាន[17]។

៧. អ្នកជំនាញរាយការណ៍ថា វេជ្ជបណ្ឌិតដែលព្យាបាល នួន ជា នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានកត់សម្គាល់ថា ការចងចាំរបស់គាត់មិនមានបញ្ហាទេ ហើយជាពិសេស បានកត់សម្គាល់ថា គាត់មាន "ការចងចាំបានល្អ" ពាក់ព័ន្ធនឹងប្រវត្តិសុខភាពរបស់គាត់នាពេលថ្មីៗកន្លងទៅ[18]។ វេជ្ជ-

---

[11] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១៧, ៤១។

[12] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៧, ១៨។ សូមមើល សេចក្តីសម្រេចលើកទីបួនទៅលើសម្បទា កថាខណ្ឌ ៦។

[13] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១៨។

[14] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៤១។

[15] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៤២។

[16] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១០។

[17] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១១។

[18] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២១-២២។

បណ្ឌិតរូបនោះ ក៏បានកត់សម្គាល់ផងដែរថា អារម្មណ៍របស់គាត់មិនមានភាពប្រែប្រួលទេ[19]។ អ្នកជំនាញយល់ឃើញថា នួន ជា អាចផ្ចង់អារម្មណ៍បានពេញលេញនៅក្នុងអំឡុងពេលសម្ភាសន៍រយៈពេល ៦០ នាទី និង កត់សម្គាល់ថា គាត់ហាក់ដូចជាមិនមានភាពនឿយហត់ ឬ មិនស្រួលខ្លួន ហើយគាត់នៅតែមានភាពរហ័សរហួន និង បានឆ្លើយតបយ៉ាងច្បាស់លាស់ចំពោះសំណួរដែលបានសួរគាត់[20]។ អ្នកជំនាញក៏បានរាយការណ៍ផងដែរថា នួន ជា ដឹងអំពីបទឧក្រិដ្ឋដែលគាត់រងការចោទប្រកាន់[21]។ លើសពីនេះទៀត នួន ជា ទទួលបានពិន្ទុលំដាប់ធម្មតា ចំពោះការពិនិត្យស្ថានភាពផ្លូវចិត្តដោយអ្នកជំនាញ ដែលជាការធ្វើតេស្តសាមញ្ញមួយសម្រាប់ពិនិត្យមើលការចុះខ្សោយនៃសតិបញ្ញា[22]។ អ្នកជំនាញកត់សម្គាល់ថា ការធ្វើតេស្តផ្នែកបញ្ញាស្មារតីជាទៀតទាត់ ក្រោមទម្រង់ជាការធ្វើតេស្តសង្ខេបផ្នែកបញ្ញាស្មារតី (AMT) ត្រូវបានធ្វើឡើងសម្រាប់ នួន ជា រៀងរាល់បីខែម្តង ហើយគាត់ទទួលបានពិន្ទុធម្មតា[23]។ ជារួម អ្នកជំនាញយល់ឃើញថា សភាពផ្លូវចិត្តរបស់គាត់មានលក្ខណៈធម្មតា ហើយការចងចាំរយៈពេលខ្លី ការផ្ចង់អារម្មណ៍ និង ការយកចិត្តទុកដាក់ គឺធម្មតាសម្រាប់អាយុរបស់គាត់[24]។ អ្នកជំនាញ យល់ឃើញផងដែរថា នួន ជា មានសមត្ថភាពចាំបាច់នានាដែលបានកំណត់នៅក្នុង*រឿងក្តី Strugar*[25]។

៨. អ្នកជំនាញកត់សម្គាល់ថា នួន ជា មានអាយុ ៨៩ ឆ្នាំ និង មានសុខភាពចាស់ទ្រុឌទ្រោម ហើយប្រឈមនឹងការចុះខ្សោយខ្លាំងលើមុខងារផ្សេងៗនៃរាងកាយ[26]។ អ្នកជំនាញបានផ្តល់អនុសាសន៍ឱ្យគាត់បន្តទទួលការព្យាបាលដោយចលនាយ៉ាងហោចណាស់ឱ្យបានម្តងទៅពីរដងក្នុងមួយសប្តាហ៍[27]។ អ្នកជំនាញក៏យល់ឃើញផងដែរថា ការចងចាំ និង មុខងារបញ្ញាស្មារតីរបស់ នួន ជា អាចនឹង

[19] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២១-២២។

[20] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២៣។

[21] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២៤។

[22] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២៥។

[23] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២០។

[24] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២៦-២៧។

[25] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២៨-៣៩។

[26] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១៦។

[27] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១៦។

មានការធ្លាក់ចុះទន់ខ្សោយបន្តិចម្តងៗជាបន្តទៅតាមអាយុរបស់គាត់[28]។ ដូច្នេះ អ្នកជំនាញណែនាំឱ្យមានការពិនិត្យមុខងារបញ្ញាស្មារតីរបស់គាត់ឱ្យបានទៀតទាត់ ជាពិសេស ប្រសិនបើឃើញថាមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់នោះ[29]។ អ្នកជំនាញស្នើថា ដើម្បីធានានូវការចូលរួមក្នុងសវនាការប្រកបដោយប្រសិទ្ធភាពបំផុតនោះ នួន ជា អាចអង្គុយលើកៅអីមានកង់ ឬកៅអីមានដៃ និងផ្អែកទៅក្រោយដើម្បីជួយទប់គាត់ នៅក្នុងអំឡុងពេលសវនាការ[30]។

## ៣. ច្បាប់ជាធរមាន

៩. ដើម្បីកំណត់ថា មានសម្បទាក្នុងការចូលរួមសវនាការ ជនជាប់ចោទត្រូវមានលទ្ធភាពក្នុងការចូលរួមសវនាការប្រកបដោយអត្ថន័យ ដែលមានន័យថា គាត់អាចអនុវត្តសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និង ឆាប់រហ័ស នៅក្នុងកម្រិតមួយដែលគាត់អាចចូលរួមបានដោយមានប្រសិទ្ធភាព និង យល់ដឹងពីផ្នែកសំខាន់ៗនៃកិច្ចដំណើរការនីតិវិធី[31]។

## ៤. សំអាងហេតុ

១០. នៅក្នុងការវាយតម្លៃនេះ អង្គជំនុំជម្រះពិចារណាទៅលើកត្តាទាំងអស់ដែលពាក់ព័ន្ធ រួមមានភស្តុតាងពីអ្នកជំនាញ ការសង្កេតរបស់អង្គជំនុំជម្រះផ្ទាល់ ផលប៉ះពាល់ទៅលើស្ថានភាពសុខភាពរបស់ជនជាប់ចោទ លទ្ធភាពនៃវិធានការអនុវត្តជាក់ស្តែងដើម្បីជួយសម្រួលផលប៉ះពាល់នៃការចុះខ្សោយ ហើយថា ជនជាប់ចោទត្រូវបានតំណាង និង ផ្តល់ការប្រឹក្សាយោបល់ពីក្រុមមេធាវីដែលមាន សមត្ថភាព។

១១. បន្ទាប់ពីបានពិនិត្យមើលទៅលើរបាយការណ៍ស្តីពី នួន ជា រួចមក អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា នួន ជា នៅតែមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ហើយនាពេលថ្មីៗនេះមិនបានទទួលរងនូវការចុះខ្សោយផ្នែកស្មារតី ឬរាងកាយ ដែលរារាំងគាត់មិនឱ្យបន្តចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០២ ទេ។

---

[28] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៤៧។

[29] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៤៧។

[30] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៤២។

[31] រឿងក្តី *Strugar* កថាខណ្ឌ ៥៥។

១២. អង្គជំនុំជម្រះនឹងបន្តកាលវិភាគសវនាការរបស់ខ្លួនដែលបានកែសម្រួល ដែលបញ្ចូលការឈប់សម្រាកពីរម៉ោងសម្រាប់អាហារថ្ងៃត្រង់ ដើម្បីអាចសម្រាកពេលថ្ងៃត្រង់បានយូរជាមុន ហើយអង្គជំនុំជម្រះនឹងដំណើរការសវនាការរៀងរាល់ថ្ងៃពីម៉ោង ៩:00 ព្រឹក រហូតដល់ម៉ោង ១១:៣0 ព្រឹក និង បន្តពីម៉ោង ១:៣0 រសៀល រហូតដល់ម៉ោង ៤:00 រសៀល ជាទូទៅ ពីថ្ងៃច័ន្ទ ដល់ថ្ងៃព្រហស្បតិ៍[32]។ អង្គជំនុំជម្រះក៏នឹងបន្តចាត់វិធានការតាមសភាពជាក់ស្តែងផងដែរ ដូចជា អនុញ្ញាតឱ្យជនជាប់ចោទចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតាមមធ្យោបាយសោតទស្សន៍ពីបន្ទប់ឃុំខ្លួនរបស់គាត់ស្ថិតនៅក្រោមសាលសវនាការ អនុលោមតាមវិធាន ៨១(៥) នៃវិធានផ្ទៃក្នុង ក្នុងករណីចាំបាច់។ អង្គជំនុំជម្រះយល់ឃើញថា វិធានការបែបនេះនឹងជួយសម្រួលបានគ្រប់គ្រាន់ដល់ការចុះខ្សោយលើស្ថានភាពសុខភាពរបស់ នួន ជា។

១៣. ដោយពិចារណាលើអនុសាសន៍របស់អ្នកជំនាញ ឱ្យធ្វើការពិនិត្យមុខងារបញ្ញាស្មារតីរបស់ នួន ជា ជាទៀតទាត់នោះ អង្គជំនុំជម្រះបង្គាប់ឱ្យបន្តការធ្វើតេស្តលើបញ្ញាស្មារតីរបស់គាត់ជារៀងរាល់ត្រីមាស។ អង្គជំនុំជម្រះយល់ឃើញថា តេស្តទាំងនេះគួរតែត្រូវបានបង្កើតឡើងដោយអ្នកជំនាញផ្ទាល់ជាបន្តទៀត គួរតែផ្លាស់ប្តូរដើម្បីកុំឱ្យលទ្ធផលទទួលរងផលប៉ះពាល់ដោយសារភាពស៊ាំទៅនឹងតេស្តនោះ និង ត្រូវយកទៅអនុវត្តដោយគ្រូពេទ្យវេជ្ជសាស្ត្រដែលបានចុះកិច្ចសន្យាផ្តល់សេវាជូនមន្ទីរឃុំឃាំង អ.វ.ត.ក ("អង្គភាពពេទ្យ")[33]។ នាពេលអនាគត ក្នុងករណីសមស្រប អង្គជំនុំជម្រះនឹងចេញដីកាបង្គាប់ឱ្យអនុវត្តទៅតាមអនុសាសន៍របស់អ្នកជំនាញ ដើម្បីបន្តការព្យាបាលដោយចលនាសម្រាប់ នួន ជា និង ជួយសម្រួលដែលនឹងអនុញ្ញាតឱ្យគាត់អង្គុយស្តាប់ក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល ទោះបីជាគាត់មានបញ្ហាឈឺខ្នងក៏ដោយ បន្ទាប់ពីកំណត់បាននូវវិធីសាស្ត្រសមស្របបំផុតក្នុងការធ្វើបែបនេះ។

**តាមសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

---

[32] សូមមើល សេចក្តីសម្រេចលើកទីបួនទៅលើសម្បទា កថាខណ្ឌ ១៤ ដែលដកស្រង់ចេញពីប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ២៥-២៦ (ភាសាអង់គ្លេស)។

[33] សូមមើល ដីកាបង្គាប់ឱ្យធ្វើតេស្តទៅលើសតិបញ្ញាស្មារតីរបស់ នួន ជា និង ខៀវ សំផន ប្រចាំត្រីមាស ឯកសារ E329/9 ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥។ ដីកាបង្គាប់ឱ្យធ្វើតេស្តទៅលើបញ្ញាស្មារតីរបស់ នួន ជា និង ខៀវ សំផន ប្រចាំត្រីមាស - សេចក្តីបញ្ជាក់ ឯកសារ E329/9.1 ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥។ ដីកាបង្គាប់ឱ្យកំណត់ពេលវេលានៃការធ្វើតេស្តទៅលើសតិបញ្ញាស្មារតីរបស់ជនជាប់ចោទ ឯកសារ E329/11 ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥។

**បញ្ជាក់ថា** ជនជាប់ចោទ នួន ជា មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។

**បង្គាប់** ឱ្យធ្វើតេស្តទៅលើមុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទ នួន ជា យ៉ាងហោចណាស់ម្តងជារៀងរាល់ត្រីមាស។

**ចាត់តាំង** អ្នកជំនាញឱ្យរៀបចំតេស្ត ដើម្បីវាយតម្លៃទៅលើមុខងារបញ្ញាស្មារតីរបស់ នួន ជា និង ធ្វើការជាមួយបុគ្គលិកអង្គភាពពេទ្យ អ.វ.ត.ក ដែលមានគុណវុឌ្ឍិ ដើម្បីអនុវត្តតេស្តទាំងនេះ និង ធ្វើរបាយការណ៍ជូនអង្គជំនុំជម្រះសាលាដំបូង។ និង

**បង្គាប់** ឱ្យអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ជួយសម្របសម្រួល និង កំណត់កាលបរិច្ឆេទនៃការធ្វើតេស្តទាំងនេះ ដែលនឹងចាប់ផ្តើមមិនឱ្យហួសពីថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៦។

ភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៦

**ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E.C.C.C & C.E.T.C

**យ៉ា សុខន**